សាលាឧទ្ធរណ៍

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ:៤៤៨/០៤-៨-២០០៩

**សាលដីកា**

លេខ:២៨(ច)/២៦-០២-២០១០

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី១២-២-២០១០ និង ប្រកាសជាសាធារណៈនាថ្ងៃទី២៦-០២-២០១០ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៤៤៨ ចុះថ្ងៃទី០៤-៨-២០០៩ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] **សុគី** ហៅ **ភ្លេន** ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកកៀនស្វាយ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃភូមិដើម [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] (ស) មានកូន០៥នាក់ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី១៣-១២-២០០៥ ឃុំខ្លួនថ្ងៃទី១៤-១២-២០០៥ ម១ ។

២-ជនជាប់ចោទឈ្មោះ [redacted] **យ៉ាភូច** ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកពីស ឃុំជ្រែក ស្រុក កំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ។(នៅក្រៅឃុំបណ្តោះអាសន្ន) ។

៣-ជនជាប់ចោទឈ្មោះ [redacted] **ចន្ថា** ភេទស្រី អាយុ៤៨ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិរា ឃុំផ្ទះរៃព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ មានដីកាចាប់ខ្លួនលេខ:៣៥០ ចុះថ្ងៃទី១៤-១២-២០០៦ ។១./

មេធាវីការពារលោក [redacted] ចន្ធា

ត្រូវចោទពីបទ:ជួញដូរមនុស្ស ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-៩-២០០៣ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់មនុស្ស, លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។

-ជនរងគ្រោះឈ្មោះ [redacted] **សំអេង** ភេទស្រី អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករកាត់ដេរ កើតនៅភូមិ [redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខក២៧ ផ្លូវ៣៦៩ សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted] រ) នៅលីវ ទោសពីមុនគ្មាន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សំអាន** (ម្តាយជនរងគ្រោះ)

តាមពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-៤-២០០៧ របស់ឈ្មោះ [redacted] **សុគី** ប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ:៣៣(ច) ចុះថ្ងៃទី១៣-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

**<u>ដំណើររឿងហេតុមានដូចតទៅ</u>**

កាលពីយប់ថ្ងៃទី០៧-៩-២០០៣ វេលាម៉ោងមិនចាំនៅខណ្ឌមានជ័យ ក្រុងភ្នំពេញ មានករណីជួញដូរមនុស្សធ្វើជាស្រីពេស្យាមួយកើតឡើង ដែលប្រព្រឹត្តដោយឈ្មោះ [redacted] **សុគី** ហៅ **ឆ្កែន** ភេទស្រី អាយុ៤៣ឆ្នាំ បានលួងលោមជនរងគ្រោះឈ្មោះ [redacted] **សំអេង** ភេទស្រី អាយុ១៨ឆ្នាំ ដោយសន្យារកការងារឱ្យធ្វើ ហើយមានប្រាក់ខែច្រើន ពេលនោះជនរងគ្រោះក៏យល់ព្រមទៅតាមឈ្មោះ [redacted] **សុគី** ដោយជិះឡានតាក់ស៊ី(ដប់ពីរកៅអី) ទៅខេត្តពោធិសាត់ រួចក៏បាននាំយកជនរងគ្រោះទៅលក់ឱ្យថៅកែផ្ទះសំណាក់ឃីហោរស្មីព្រះចន្ទ ឈ្មោះ [redacted] **ចន្ធា** ភេទស្រី អាយុ៤៨ឆ្នាំ ហើយបានចាប់បង្ខំឱ្យជនរងគ្រោះឈ្មោះ [redacted] **សំអេង** ដេកជាមួយឈ្មោះ [redacted] **យ៉ាភូច** ភេទប្រុស អាយុ៤៤ឆ្នាំ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុគី** ហៅ **ឆ្កែន** ថា: ខ្លួនស្គាល់ជនរងគ្រោះព្រោះនៅផ្ទះជិតគ្នា នៅថ្ងៃកើតហេតុជនរងគ្រោះបានមកដេកនៅផ្ទះខ្លួនមួយយប់ ព្រោះខឹងម្តាយវា ហើយខ្លួនណែនាំឱ្យជនរងគ្រោះទៅផ្ទះវិញទៀតផង ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] **ចន្ធា** ទេ ហើយក៏មិនដែលទៅខេត្តពោធិសាត់ដែរ ។ ខ្លួនមិនដែលបានលួងលោមជនរងគ្រោះ យកទៅលក់ឱ្យគេនៅខេត្តពោធិសាត់ទេ ខ្លួនមិនដឹងរឿងអ្វីទេ ខ្លួនគ្មានភស្តុតាងមកសំអាងក្នុងរឿងនេះទេ ហើយក៏គ្មានសាក្សីមកបញ្ជាក់ដែរ ។

-តាមចម្លើយឈ្មោះ [redacted] **យ៉ាភូច** បានឆ្លើយថា: ខ្លួនបានទៅលេងនៅផ្ទះសំណាក់រស្មីព្រះច័ន្ទ នៅខេត្តពោធិ៍សាត់ ដែលមានបើកខារ៉ាអូខេមានស្រីៗជាច្រើន ប្រហែលជា៣០នាក់ បំរើភ្ញៀវនៅទីនោះ បាងនោះនៅទីរួមខេត្តពោធិ៍សាត់ ។ នៅពេលនោះខ្លួនបានរួមភេទជាមួយស្រីម្នាក់ដោយគ្មានការបង្ខិតបង្ខំទេ ក្នុងតំលៃ២០០០០៛✓

រៀល(ពីរម៉ឺនរៀល) ។ នៅពេលឆែកឆេរនៅផ្ទះសំណាក់នៅខេត្តពោធិ៍សាត់នោះ គឺខ្លួនជាអ្នកជូនសមត្ថកិច្ច និង អង្គការសិទ្ធិមនុស្ស ទៅសង្គ្រោះបាននារីម្នាក់ឈ្មោះ [redacted] **សំអេម** ទៀតផង ។

-តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] **សំអេម** បានឆ្លើយថា: ខ្លួនស្គាល់ឈ្មោះ [redacted] **សុភី** ហៅ **ភ្លេន** ព្រោះនៅផ្ទះជិតគ្នា ឈ្មោះនេះបានមកទាក់ទងខ្លួនថាជួយរកការងារឱ្យធ្វើ ការងារនោះស្រួលៗទៅតែបានលុយច្រើន ។ ឈ្មោះ **ភ្លេន** បានមកលួងលោមខ្លួននៅកន្លែងលក់បង្អែម ខ្លួនមិនដែលដេកនៅផ្ទះឈ្មោ[redacted] **សុភី** ហៅ **ភ្លេន** ទេ ហើយឈ្មោះនេះបាននាំខ្លួនជិះឡាននៅផ្សារថ្មី ទៅខេត្តពោធិសាត់ ដោយយកខ្លួនទៅធ្វើការនៅផ្ទះសំណាក់ រស្មី ព្រះច័ន្ទ ។ ពេលចេញដំណើរពីភ្នំពេញនៅវេលាល្ងាច ពេលទៅដល់ពោធិសាត់ប្រហែលរយៈពេល០៣ខែ ខ្លួនមិន ស្គាល់ថៅកែហាងទេ មិនស្គាល់ភិនភាគច្បាស់លាស់ទេ ថៅកែនោះរាងធាត់ទាប សម្បុរស ផ្ទះថៅកែសង់ពីថ្ម គេឱ្យ ខ្លួននៅក្នុងបន្ទប់ដោយចាក់សោរជាប់ ។ ពេលដែលខ្លួនដេកជាមួយឈ្មោះ [redacted] **យ៉ាំភួច** នោះ ខ្លួនបានសុំទូរស័ព្ទ គាត់ហៅទៅអ្នកគ្រូរបស់ខ្លួន ដែលធ្លាប់បង្រៀនខ្លួននៅអង្គការចំនួនប្រហែលជា៣ដង ដោយខ្លួនបាននិយាយដំណើរ រឿងឱ្យអ្នកគ្រូស្តាប់ ហើយក្រោយមកក៏មានអង្គការរួមជាមួយសមត្ថកិច្ច បានមករំដោះខ្លួនពីកន្លែងផ្ទះសំណាក់ រស្មីព្រះច័ន្ទ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៣៣(ច) ចុះថ្ងៃទី១៣-៣-២០០៧ របស់សាលាដំបូងរាជធានី ភ្នំពេញ មានខ្លឹមសារដូចតទៅ :

១-ឱ្យឈ្មោះ[redacted] **យ៉ាំភួច** ភេទប្រុស អាយុ៤៤ឆ្នាំ រួចផុតពីបទចោទពីបទ:ជួញដូរមនុស្ស ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៩-២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា៣ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស ។

២-ផ្តន្ទាទោសឈ្មោះ[redacted] **សុភី** ហៅ ភ្លេន ភេទស្រី អាយុ៤៣ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ(ដប់ពីរ ឆ្នាំ) គិតពីថ្ងៃឃុំខ្លួន១៤-១២-២០០៥ ពីបទ:ជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៩-២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។

៣-ផ្តន្ទាទោសឈ្មោះ[redacted] **ចន្ថា** ភេទស្រី អាយុ៤៨ឆ្នាំ ដាក់ពន្ធនាគារកំណត់១២ឆ្នាំ(ដប់ពីរឆ្នាំ) គិតពី ថ្ងៃចាប់ខ្លួនបាន ពីបទ:ជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៩-២០០៣ តាមមាត្រា៣ នៃច្បាប់ ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។

៤-បង្គាប់ឱ្យឈ្មោះ [redacted] **សុភី** និងឈ្មោះ [redacted] **ចន្ថា** រួមគ្នាសងសំណងជូសជុលការខូចខាត និង ជម្ងឺ ចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សំអាន** ចំនួន១០០០ដុល្លាអាមេរិក(មួយពាន់ដុល្លាអាមេរិក) ។ ក្នុងករណីរឹងរូសពុំព្រមសង ត្រូវដាក់គុកបង្ខំដល់រូបកាយដើម្បីទារប្រាក់ធនទណ្ឌនេះ តាមមាត្រា៦ និង ៧ នៃច្បាប់ ស្តីពីការដាក់គុកបង្ខំដល់រូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

១៥៤

៣-សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **យ៉ាំភួច** ឈ្មោះ [redacted] **សុគី** ហៅ **ឡេន** មេធាវីការពារជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ឈ្មោះ[redacted] **ចន្ថា** បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញរបាយការណ៍រឿង ចុះថ្ងៃទី១៤-១០-២០០៩ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២១-១២-២០០៩ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted] **សុគី** ( អវត្តមាន)

-មេធាវីការពារជនជាប់ចោទ លោក[redacted] **ចន្ថា** ( វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]**សំអាន** ( អវត្តមាន)

ប្រធានក្រុមប្រឹក្សាសួរយោបល់តំណាងមហាអយ្យការ

តំណាងមហាអយ្យការ និង មេធាវីការពារជនជាប់ចោទ សុំឱ្យលើករឿងមកជំរះកំបាំងមុខ ។

-ប្រធានក្រុមប្រឹក្សាធ្វើសេចក្តីសង្ខេបរឿង

-តំណាងមហាអយ្យការសន្និដ្ឋានថាៈ សុំឱ្យតំកល់សេចក្តីសំរេច នៃសាលក្រមព្រហ្មទណ្ឌលេខៈ៣៣(ច) ចុះថ្ងៃទី១៣-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញដដែល និង សុំឱ្យកែតំរូវមាត្រាច្បាប់ឱ្យបានត្រឹមត្រូវ ។

-មេធាវីការពារជនជាប់ចោទសន្និដ្ឋានថាៈ ការចោទប្រកាន់កូនក្តីខ្លួនឃើញថាត្រឹមត្រូវហើយ តែសុំឱ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស ដល់កូនក្តីខ្លួនផង ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារដែលពាក់ពន្ធ័

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

១-យល់ឃើញថាៈ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-០៤-២០០៧ របស់ឈ្មោះ[redacted] **សុគី** ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយ៉ាងតាមបញ្ញត្តិមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថាៈ តាមការបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] **សំអេទ** បានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] **សុគី** បានលួងលោមជនរងគ្រោះ ដោយបានប្រាប់ជនរងគ្រោះថា ខ្លួនជួយរកការងារឱ្យធ្វើដោយទទួលបានប្រាក់ខែច្រើន ហើយជនជាប់ចោទក៏បាននាំជនរងគ្រោះទៅលក់ឱ្យម្ចាស់ផ្ទះសំណាក់ រស្មីព្រះច័ន្ទ នៅឯខេត្តពោធិសាត់ ហើយម្ចាស់ផ្ទះសំណាក់នេះបានបង្ខំជនរងគ្រោះ ទុកឱ្យបំរើសេវាផ្លូវភេទជាមួយភ្ញៀវ អស់/.

១៥៣

រយៈពេលជាងបីខែ ទើបជនរងគ្រោះបានខ្ចីទូរសព្ទ័ភ្ញៀវឈ្មោះ [redacted] **យ៉ាភួច** ទូរស័ព្ទមកអ្នកគ្រូរបស់ខ្លួន ទើបអ្នកគ្រូបានប្តឹងសមត្ថកិច្ចចុះទៅរំដោះជនរងគ្រោះ ពីផ្ទះសំណាក់រស្មីព្រះច័ន្ទបានតែម្តង ។

៣-យល់ឃើញថាៈ មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] **សុតី** ពីបទៈជួញដូរមនុស្ស ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៧-៩-២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និង លក់ដូរមនុស្ស និង ធ្វើអាជីវកម្មលើមនុស្ស ។

៤-យល់ឃើញថាៈ រឿងក្តីនេះសាលាដំបូងក្រុងភ្នំពេញ បានធ្វើការអង្កេត និង លើកយកភស្តុតាង មកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូចនេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៥-យល់ឃើញថាៈ សាលក្រមព្រហ្មទណ្ឌលេខៈ៣៣(ច) ចុះថ្ងៃទី១៣-៣-២០០៧ របស់សាលាដំបូងក្រុងភ្នំពេញ ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតំកល់ទុកជាបានការដដែល ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១២-៤-២០០៧ របស់ឈ្មោះ[redacted] **សុតី** ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខៈ៣៣(ច) ចុះថ្ងៃទី១៣-៣-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-សំរេចឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **សុតី** ហៅ **ឡេន** នេះជាបន្ត ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។

**សាលដីកានេះចូលជាស្ថាពរ និង មានអានុភាពអនុវត្តទៅលើឈ្មោះ [redacted] សុតី ហៅ ឡេន ដែលប្តឹងឧទ្ធរណ៍ប៉ុណ្ណោះ ។**

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យសំរេចតាមសាលដីកាស្ថាពរនេះ និង ឱ្យអាជ្ញាធរសាធារណៈ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

បានឃើញ
**ប្រធានសាលាឧទ្ធរណ៍**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ,ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០13
**ក្រឡាបញ្ជី**

១៥៨

[redacted]